# សន្ទានុក្រម

**ជម្ងឺអេដស (AIDS)**

ដែលមានរោគសញ្ញាថា ប្រពន្ធសាំងចុះខ្សោយ មិនអាចប្រឆាំងនិង មេរោគនៃជម្ងឺមួយជំពូក របស់ប្រព័ន្ធប្រឆាំង និងមេរោគដែលបណ្តាល មកពីមេរោគ HIV ៖ហើយមិនមានថ្នាំចាក់ការពារ ឬថ្នាំព្យាបាលជម្ងឺ នេះទេ។

**ការរួមសង្វាសតាមគូថ (Anal Sex)**

នៅពេលដែលបុរសដាក់លឹង្គរបស់គេ ចូលទៅក្នុងរន្ធគូថរបស់ដៃគូ បុរស ឬស្ត្រី សំរាប់ការស្រើបស្រាល។

**អង្គបដិបក្ខ (Anti-body)**

ប្រដាប់របស់ប្រព័ន្ធការពារខ្លួន ដែលប្រឆាំងនិងមេរោគឆ្លងឬជម្ងឺ ក្លាយ។

**ថ្នាំប្រឆាំង ឬបន្ថយមេរោគ រ៉េវីរ៉េស (Anti-retroviral Drug)**

ថ្នាំម្យ៉ាងប្រើសម្រាប់ទប់ទល់នឹងមេរោគ HIV ។

**ដែលមិនបង្ហាញ ឬគ្មានរោគ សញ្ញា (Asymtonatic)**

នៅពេលដែលមនុស្សណាម្នាក់មានជម្ងឺក្លាយ តែគ្មានបង្ហាញនូវរោគ សញ្ញា មនុស្សនោះប្រហែលជាពុំដឹងថាខ្លួនមានជម្ងឺ ។

**ទឹកក្រេស៊ីល (Bleach)**

ថ្នាំសម្រាប់ដាក់ឱ្យខោអាវស្អាត។

**ប៊ូលប៊ីលលីង (Bulk billing)**

របៀបគិតលុយដោយមានជំនួយពីរដ្ឋាភិបាល ចំពោះអ្នកដែលមាន ប័ណ្ណមីឌីឃែ ហើយអ្នកមិនបាច់បង់លុយទេ ពេលទៅជួបពេទ្យ

**កោសិកា (Cell)**

ផ្នែកដ៏តូចបំផុតនៃខ្លួនមនុស្ស។ ខ្លួនមនុស្ស គឺបង្កើតឡើងដោយកោសិការាប់លាន។ កោសិកាគឺតូចរហូតដល់មិនអាចមើលនិងភ្នែកឃើញ។

**ស្រោមលឹង្គ ឬស្រោមអនាម័យ (Condom)**

ស្បោងជ័រដ៏ស្តើង ដែលត្រូវនឹងលឹង្គបុរសពេលឡើងរឹង (ដូចស្រោមដៃជ័រត្រូវនឹង ដៃ)។ គេប្រើវាដើម្បីការពារកុំឱ្យមានផ្ទៃពោះនិងកុំឱ្យឆ្លងជម្ងឺតាមការរួមសង្វាស។

**ការរក្សាការសម្ងាត (Confidentiality)**

ច្បាប់ដែលបញ្ឈប់អ្នកធ្វើការសុខភាព វេជ្ជបណ្ឌិត និងអ្នកបកប្រែ មិនឱ្យនិយាយ ប្រាប់គេឯង អំពីពត៏មានដែលអតិថិជនបានប្រាប់គេ។ អ្នកធ្វើការទាំងនេះអាច និយាយប្រាប់រឿងដែលអតិថិជនប្រាប់គេបាន បើមានការអនុញ្ញតពីអតិថិជន ឬក្នុងកាលៈទេសៈសំខាន់ចាំបាច់។

**ឆ្លង (Contagious)**

ជម្ងឺក្លាយដែលអាចឆ្លងពីម្នាក់ទៅម្នាក់ទៀត។

**អ្នកផ្តល់យោបល់ (Counsellors)**

អ្នកធ្វើការ ដែលមានការជំនាញផ្នែក និយាយនិងស្តាប់ពីរឿង ឬបញ្ហា ធ្វើឱ្យអ្នកព្រួយចិត្ត និងជំនាញការផ្នែករកដំណោះស្រាយជូន។ អ្នកផ្តល់ យោបល់ គឺប្រកាន់ច្បាប់រក្សាការសម្ងាត់យ៉ាងហ្មត់ចត់។

**សន្ទះទប់ (Dam)**

បន្ទះជ័រដ៏ស្តើងបួនជ្រុង ប្រើសម្រាប់ទ្រាប់ពីលើយោនី ឬរន្ធគូថ របស់មនុស្សប្រុស ឬ ស្រីពេលរួមសង្វាសតាមមាត់។

**រោគវិនិច្ឆ័យ (Diagnosis)**

អ្វីដែលវេជ្ជបណ្ឌិតសម្រេចចិត្តបន្ទាប់ពីមើលរោគសញ្ញាអ្នកជម្ងឺ និង ប្រវត្តិជម្ងឺ ារសម្រេចចិត្តចុងបញ្ចប់របស់វេជ្ជបណ្ឌិត បន្ទាប់ពីធ្វើការ ពិនិត្យធ្វើតេស្ត ឬ ក៏ និយាយជាមួយអ្នកជម្ងឺ។

**ការរើសអើង (ការប្រកាន់) (Discrimination)**

ការវាយតម្លៃនរណាម្នាក់ដោយមានភាពលំអៀង ឬ មិនសមរម្យ ពីព្រោះអ្នក នោះមានភាពខុសពីខ្លួន។ ឧទាហរណ៍ ជនអន្តោប្រវេសន៍ ស្ត្រី មនុស្សមានរោគ HIV ឬជម្ងឺ AIDS មនុស្សពិការ។ល។

**ជម្ងឺ (Disease)**

មកពីពាក្យឈឺ។

**ការស៊ាំនិងថ្នាំ (Drug resistance)**

នៅពេលដែលប្រព័ន្ធ ឬក៏ខ្លួនប្រាណយើងស៊ាំនឹងជាតិថ្នាំ ដែលធ្វើឱ្យ ជាតិថ្នាំមិនមានប្រសិទ្ធិភាព។

### មនុស្សប្រុសស្រឡាញ់ មនុស្សប្រុស (Gay)

ពាក្យសម្រាប់ប្រើទៅលើមនុស្សប្រុស ដែលចាប់ចិត្តទៅលើមនុស្សប្រុសដូចគ្នា ឬ ក៏រួមសង្វាសជាមួយបុរសដូចគ្នា សមាជិករបស់សមាគមន៍ប្រុសស្រឡាញ់ប្រុស។

### ប្រដាប់បន្តពូជ (Genitals)

ផ្នែកនៃរាងកាយរបស់មនុស្ស។ ដូចជាមនុស្សប្រុសមានលឹង្គ មនុស្សស្រីមានយោនី បបូរមាត់យោនី។

### ជម្ងឺប្រមេះ (Gonorrhea)

គឺជាជម្ងឺដែលអាចឆ្លងបាន តាមការរួមសង្វាសមិនប្រុងប្រយ័ត្ន។ យើងអាចការពារបាន ដោយសារការប្រើស្រោមលឹង្គ នៅពេលរួមសង្វាស និងអាចព្យាបាល ដោយប្រើថ្នាំអង់ទីបាយយូវទីក (Antibiotics)។

### ជម្ងឺរលាកថ្លើម (Hepatitis)

រោគហើមថ្លើមដែលជាទូទៅ បណ្តាលមកពីមេរោគវៃរើសថ្លើម។ ជំពូកហើមថ្លើមដែលកាចបំផុតគឺ ជំពូក ក ខ និង គ។

### ដែលស្រឡាញ់មនុស្ស ដែលមានភេទផ្ទុយគ្នា (Heterosexual)

ពាក្យសម្រាប់ប្រើទៅលើនរណាម្នាក់ ដែលទាក់ចិត្តជាមួយឬរួម សង្វាសជាមួយមនុស្សដែលមានភេទផ្ទុយគ្នា។

### ហេច្ឆអាយវី (HIV)

មរោគ (វៃរើស) ដែលធ្វើឱ្យប្រព័ន្ធប្រឆាំងនិងមេរោគក្នុងខ្លួនខ្សោយ មេរោគនេះហើយដែលធ្វើឱ្យមានជម្ងឺអែដស។ ហេច្ឆអាយវី គឺជាជម្ងឺឆ្លង តាមការរួមសង្វាស និង ឆ្លងនៅពេលដែលឈាម អ្នកមានមេរោគ HIV ចូលទៅតាមសរសៃឈាមអ្នកដែលអត់មេរោគ HIV ពីម្តាយទៅកូន នៅពេលមានផ្ទៃះពោះ ពេលឆ្លងទន្លេ ឬ ពីទឹកដោះម្តាយ។

### ហេច្ឆអាយវី វិជ្ជមាន (HIV Positive)

មនុស្សដែលពិនិត្យឃើញមានមេរោគហេច្ឆអាយវីនៅក្នុងឈាមរបស់គេ ក្រោយពេលដែលពួកគេបានឆ្លងមេរោគ HIV។ ពាក្យភូស៊ីទីវ (Positive) ត្រូវបានប្រើនៅពេលដែលគេពិនិត្យឃើញមានមេរោគហេច្ឆអាយវីនៅក្នុងខ្លួន។

### ហេច្ឆអាយវី អវិជ្ជមាន (HIV Negative)

ពាក្យនេហ្គាទីវ ឬអវិជ្ជមាន(Negative)គឺពុំមាន។ ហេអាយវីអវិជ្ជមាន គឺមានន័យថាអ្នកនោះមិនមានមេរោគ ហេអាយវីទេ។

### ថ្នាំឬពិធីព្យាបាលម្យ៉ាង (Homocopathy)

ពិធីព្យាបាលដោយប្រើថ្នាំដែលបង្កើតឡើងក្នុងមនុស្សដែលមានរោគសញ្ញាស្រដៀងនិងជម្ងឺ។

### មនុស្សរួមសង្វាសជា មួយមនុស្សភេទដូចគ្នា (Homosexual)

ពាក្យសម្រាប់ប្រើទៅលើ មនុស្សប្រុសដែលទាក់ចិត្តជាមួយ ឬក៏រួមសង្វាសជា មួយប្រុសដូចគ្នា។ មនុស្សស្រីចាប់ចិត្តជាមួយ ឬក៏រួមសង្វាសជាមួយស្រីភេទ ដូចគ្នា។

### ប្រព័ន្ធការពារ ឬប្រ ឆាំងមេរោគក្នុងខ្លួន (Immune System)

ប្រព័ន្ធក្នុងខ្លួនសម្រាប់ប្រឆាំងនឹងជម្ងឺឆ្លង នឹងមេរោគផ្សេងៗ។ HIV គឺជាមេរោគ ដែលបំផ្លាញផ្នែកនៃប្រព័ន្ធការពារ ឬប្រឆាំងនិងមេរោគក្នុងខ្លួន ដូច្នេះហើយទើប មនុស្សមានមេរោគពុំអាចទប់ទល់នឹងជម្ងឺ ឆ្លងបាន។

### ការឆ្លង ឬ ក្លាយ (Infection)

ការលូតលាស់រាលដាលនៃមេរោគនៅក្នុង ឬលើខ្លួន។ ការក្លាយទាំងនេះអាច បណ្តាលមកពីវៃរើស បាក់ទេរី ជាតិផ្សិត ឬ ប៉ារ៉ាស៊ីត។

### សេចក្តីអនុញ្ញាតដោយ ដឹងច្បាស់ លាស់ (Informed Consent)

នៅពេលដែលមនុស្សម្នាក់យល់ព្រមធ្វើតេស្តអ្វីមួយ ឬក៏ទទួលការព្យាបាលអ្វីមួយ អ្នកនោះ (អ្នកជម្ងឺ) ត្រូវតែយល់ព្រមនូវការព្យាបាល មុននឹងការព្យាបាលចាប់ផ្តើម។ អ្នកជម្ងឺត្រូវតែទទួលពត៌មានគ្រប់គ្រាន់ដូចដែលគេត្រូវការ មុននឹងធ្វើការសម្រេចចិត្តទទួលការព្យាបាល។

### ជនប្រើគ្រឿងញៀនចាក់ (Injecting drug user) (IDU)

ពាក្យសម្រាប់ពិពណ៌នា មនុស្សដែលប្រើថ្នាំញៀនដោយប្រើម្ជុលហើយនិងស៊ីរាំង ដើម្បីចាក់ថ្នាំញៀនចូលទៅក្នុងសសៃឈាមខ្លួន ឬសាច់ដុំ។

### ស្រីរួមសង្វាសជាមួយស្រី (Lesbian)

ពាក្យសម្រាប់ប្រើទៅលើស្ត្រីដែលចាប់ចិត្ត ឬក៏រួមសង្វាសជាមួយស្ត្រីដូចគ្នា។ សមាជិកនៃសមាគមន៍ ស្រីស្រឡាញ់ស្រី។ ចូលមើលនៅក្នុងមនុស្សរួមសង្វាសជា មួយមនុស្សភេទដូចគ្នា។ ទាំងនេះមិនឆ្លងទៅមនុស្សដែលមានសុខភាពល្អឡើយ។

រំអិល (Lube or Lubricant)

វត្ថុរាវម្យ៉ាងរំអិល។ នៅពេលដែលយើងនិយាយអំពី ការរួមសង្វាស ដោយប្រុងប្រយ័ត្ន ទឹករំអិលគឺជា វត្ថុរាវម្យ៉ាងធ្វើអំពីទឹក (ចៅហ៊ួយ) ដែលគួរតែយកមកប្រើជាមួយស្រោមលឹង្គ ដើម្បីកុំឱ្យស្រោមលឹង្គដាច់ ឬរហែក។

បន្ទះស្បែក (Mucosa)

សន្ទះស្បែកស្តើងៗពិសេសមាននៅលើលឹង្គ យោនី ឬរន្ធគូថ

កិច្ចបំរើផ្នែកប្តូរម្ជុល (Needle Exchange Service)

កិច្ចបំរើដែលអ្នកអាចយកម្ជុល និងស៊ីរ៉ាំងដោយឥតគិតថ្លៃ ហើយមានកន្លែងចោល ម្ជុលដែលអ្នកប្រើរួចហើយ។

រោគឆ្លង ឬ ក្លាយ នៅពេលយើង ខ្សោយ (Opportunistic Infection)

រោគឆ្លង ឬក្លាយដែលរាលដាលយ៉ាងឆាប់រហ័សដោយសារប្រព័ន្ធ ការពារ ឬប្រឆាំងនិងមេរោគទន់ខ្សោយ។ ប្រព័ន្ធការពារប្រឆាំងនឹងមេរោគអាចចុះខ្សោយ ដោយសារតែមេរោគ HIV។ រោគឆ្លង ឬក្លាយទាំងនេះ មិនឆ្លងទៅមនុស្សដែលមានសុខភាពល្អឡើយ។

ការរួមសង្វាសតាមមាត់ (Oral Sex)

នៅពេលដែលគេធ្វើឱ្យដៃគូគេស្រើបស្រាលដោយប្រើមាត់ លិត ជញ្ជក់ បឺត យោនីឬលិង្គ។

វិជ្ជាពេទ្យកុមារ (Paediatric)

វេជ្ជបណ្ឌិតជំនាញផ្នែកជម្ងឺកូនង៉ា និងកូនក្មេង។

លឹង្គ (Penis)

ប្រដាប់បន្តពូជរបស់បុរស។

ការដាក់ចូលតាមផ្លូវកាម (Penetration)

ការដាក់លឹង្គរឹងចូលទៅតាមមាត់ រន្ធគូថ ឬ យោនី។

ជនរស់នៅជាមួយមេរោគ (Poeple living with HIV)

មនុស្សដែលបានឆ្លងមេរោគហេច្ចអាយវី។ មនុស្សមានមេរោគ ហេច្ច អាយវីអាចកើតជម្ងឺអេដស៍នៅពេលអនាគត។

ពិធីព្យាបាលដោយការពារ (Prophylaxis)

ជាពិធីការពារខ្លួនកុំឱ្យឆ្លងរោគផ្សេងៗ នៅពេលដែលប្រព័ន្ធការពារប្រឆាំងមេរោគក្នុងខ្លួនយើងខ្សោយ។

ការរួមសង្វាសដោយការពារ (Protected sex)

ប្រើស្រោមលឹង្គ ពេលរួមដំណេកដើមកាពោរមេរោគ ហេច្ចអាវី និង ជម្ងឺឆ្លងតាមភេទផ្សេងៗ។

អ្នកចិត្តវិជ្ជា (psychologists)

អ្នកជំនាញការផ្នែកផ្លូវចិត្ត ដែលអាចផ្តល់យោបល់ និង រកដំណោះស្រាយជូន ពេលអ្នកព្រួយ ឬពិបាកចិត្ត។

ការរួមសង្វាសដោយប្រុង ប្រយ័ត្នឬគ្មានគ្រោះថ្នាក់ (Safe Sex)

នៅពេលដែលរួមសង្វាសដោយមិនមានគ្រោះថ្នាក់នៃការឆ្លង ឬក៏ចម្លងនៃមេរោគ ឬមេរោគឆ្លងនានាតាមការរួមសង្វាស។

ទឹកកាម ឬទឹកអង្គាតិ (Semen or Sperm)

វត្ថុរាវដែលចេញពីលឹង្គនៅពេលដែលបុរសស្រើបស្រាលដល់កំពូល។

ការរួមសង្វាស (Sexual Intercourse)

មើលតាមកន្លែង "ការដាក់ចូលតាមផ្លូវកាម" (Pentration)។

សុខភាពផ្នែកកាម (Sexual Health)

សមត្ថភាពរបស់បុរស ឬស្ត្រីក្នុងការសប្បាយ និងការស្រើបស្រាលផ្នែកភេទ ដោយមិនមានគ្រោះថ្នាក់ ឬឆ្លងមេរោគតាមការរួមសង្វាស មានផ្ទៃពោះដោយពុំបានគ្រោងទុក ភាពកាចសាហាវ ឬភាពរើសអើង។

ជម្ងឺឆ្លងតាមការរួមសង្វាស (Sexual transmitted disease) ( STD )

ជម្ងឺដែលអាចឆ្លងពីម្នាក់ ទៅម្នាក់ទៀតតាមការរួមសង្វាស។

ផលអាក្រក់នៃថ្នាំ ឬ ការព្យាបាល (Side effect)

ជាលទ្ធផលនៃការញាំថ្នាំ ឬការព្យាបាល ជាពិសេសការញាំថ្នាំដែលមិនចាំបាច់។

បុគ្គលិកបំរើសង្គម (Social workers)

អ្នកធ្វើការដែលមានការជំនាញផ្នែក និយាយ ស្តាប់ និងរកដំណោះស្រាយពីរឿង ឬបញ្ហាដែលធ្វើឱ្យអ្នកព្រួយចិត្ត។

### តេស្ត (Test)

វិធីរកមុខជម្ងឺដោយយកឈាម ឬក៏វត្ថុរាវនៃខ្លួនមនុស្ស ទៅពិនិត្យមើលយ៉ាងហ្មត់ចត់។

### អ្នកប្តូរភេទ (Transgender)

មនុស្សដែលធ្វើការវះកាត់ ឬប្រើអ័រម៉ូនដើម្បីធ្វើខ្លួនគេឱ្យទៅជាភេទផ្សេង ឧទាហរណ៍ ប្រុសកែភេទទៅជាស្រី ឬស្រីកែភេទទៅជាប្រុស។

### ការចម្លង (Transmission)

ការឆ្លងមេរោគពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត។

### ការព្យាបាល (Treatment)

អ្វីដែលមនុស្សធ្វើដើម្បីឱ្យខ្លួនមានសុខភាពល្អ ឬប្រសើរឡើង។ ការព្យាបាលទាំង នេះអាចរួមបញ្ចូលទាំងការប្រើថ្នាំពេទ្យ ថ្នាំចិន ថ្នាំ  បុរាណ ឬក៏ប្តូរនៅការរស់នៅប្រចាំថ្ងៃ។

### រួមសង្វាសដោយ មិនប្រុង ប្រយ័ត្ន (Unprotected Sex)

រួមសង្វាសដោយគ្មានប្រើស្រោមលឹង្គ ឬប្រដាប់ទ្រាប់។

### យោនី (Vagina)

ផ្នែកភេទរបស់ស្ត្រី (ប្រដាប់បន្តពូជរបស់ស្ត្រី)។

### ទឹកយោនី (Vagina Fluid)

ទឹករំអិលធម្មជាតិនៅក្នុងយោនី ។

### ចំនួននៃមេរោគ (Viral Load)

ចំនួននៃវៃរើស (ឧ. ហេច្ឆអាយវី ឬជម្ងឺថ្លើមជំពូក C) ដែលរកឃើញនៅក្នុងឈាមរបស់មនុស្ស បើសិនជាពួកគេត្រូវបានឆ្លងវៃរើស។

### វៃរើស (Virus)

មេរោគដែលថ្នាំផ្សះមិនអាចព្យាបាលបាន។ ហេច្ឆអាយវី និងជម្ងឺថ្លើម ជំពូក A, B, និង C គឺជាវៃរើស។